# សេចក្តីប្រកាសព័ត៌មាន

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី មានកិត្តិយសសូមជម្រាបជូនដំណឹងដល់វិនិយោគិន និងសាធារណជនទាំងអស់មេត្តាជ្រាបថា អិលអូអិលស៊ីនឹងពន្យាពេលផ្សព្វផ្សាយរបាយការណ៍ប្រចាំត្រីមាសទី១ ឆ្នាំ២០២០ រហូតដល់ ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ ដោយមូលហេតុដូចខាងក្រោម៖

១. សម្រាប់ឆ្នាំសារពើពន្ធ ២០២០ អិលអូអិលស៊ីបានធ្វើការផ្លាស់ប្តូរស្នងការគណនេយ្យឯករាជ្យ ដោយអនុលោមទៅតាមតម្រូវការរបស់ធនាគារជាតិនៃកម្ពុជា ដែលតម្រូវឱ្យធ្វើការផ្លាស់ប្តូរស្នងការគណនេយ្យឯករាជ្យរៀងរាល់ ៣ឆ្នាំម្តង ធ្វើឱ្យក្រុមហ៊ុនសវនកម្មឯករាជ្យថ្មីត្រូវការពេលវេលាច្រើន ដើម្បីត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុរបស់អិលអូអិលស៊ីឡើងវិញ។

២. ដោយសារតែផលប៉ះពាល់ពីមេរោគ Covid-19 ជាបញ្ហាប៉ះពាល់ជាសាកល ដូច្នេះ ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិបានតម្រូវឱ្យបញ្ចូលផលប៉ះពាល់បណ្តាលមកពី Covid-19 ទៅក្នុងការគណនាសំវិធានធន អនុលោមតាមស្តង់ដារគណនេយ្យ IFRS 9។ អាស្រ័យហេតុនេះ អិលអូអិលស៊ីបានចុះកិច្ចសន្យាជាមួយក្រុមហ៊ុន Deloitte (Cambodia) Co, Ltd. ដើម្បីអភិវឌ្ឍ IFRS 9 Tools ដែលបញ្ចូលផលប៉ះពាល់ពី Covid-19។ ដូច្នេះ បន្ទាប់ពីក្រុមហ៊ុន Deloitte អភិវឌ្ឍ IFRS 9 Tools រួចរាល់ហើយ ក្រុមហ៊ុនសវនកម្ម PWC ត្រូវការពេលវេលាដើម្បីត្រួតពិនិត្យលើ IFRS 9 Tools នោះ ដើម្បីធានាបាននូវភាពត្រឹមត្រូវ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមវិនិយោគិន និងសាធារណជនទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃសុក្រ ៩រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០




---

## Press Release

LOLC (Cambodia) Plc. (“LOLC”) is pleased to formally announce to the investors and public that LOLC will delay the publishing of Q1-2020 Report until 29th May 2020 due to the following reasons:

1. For fiscal year 2020, LOLC has changed its external auditor in compliance with the requirement of the National Bank of Cambodia, which requires to change external auditor every 3 years, making the new external auditor needs much time to review all financial reports of LOLC.

2. Due to Covid-19 is a global issue, IFRS standards are required to incorporate impacts of Covid-19 in the calculation of provision in accordance with IFRS 9 accounting standards. In terms of this, LOLC has engaged with Deloitte (Cambodia) Co, Ltd. to develop IFRS 9 tools that incorporate the impacts of Covid-19. So, after Deloitte develops IFRS 9 tools, PWC external auditor needs time to review that IFRS 9 tools to ensure accuracy.

As stated above, please kindly be informed.

Phnom Penh, 15th May 2020

